# តើខ្ញុំត្រូវគ្រប់គ្រងអ្នកម៉ៅការ និងបុគ្គលិកដែលចេញចូល ចំការទំពាំងបាយជូររបស់ខ្ញុំ ដោយរបៀបណា?

# Phylloxera
## Stop the Spread!

នៅជើងសម្អាត និងការរម្ងាប់សត្វចង្រៃលើគ្រឿងសម្រាប់ពាក់ មុនពេលចូលចំការទំពាំងបាយជូរ



**លាយទឹកថ្នាំធ្វើឱ្យសសម្រាប់ប្រើប្រាស់នៅផ្ទះ ជាមួយទឹកក្នុងធុងមួយ ដើម្បីធ្វើជាល្បាយ។**
រូវការសម្រាប់លាយគឺទឹកថ្នាំធ្វើឱ្យស ៥០ភាគរយ ទឹក៥០ភាគរយ ដើម្បីសម្លាប់សត្វល្អិត phylloxera បានដោយប្រសិទ្ធិភាព។ សូមពិនិត្យមើលស្លាក - គ្រឿងផ្សំសកម្មចាំបាច់ត្រូវមានសារធាតុ sodium hypochlorite ( សូដ្យូម ហ៊ីប៉ូខ្លូរីត )។



**លាងត្រដុសស្បែកជើងកវែងក្នុងទឹកស្អាត**



**ត្រាំ ហើយលាងត្រដុសស្បែកជើងកវែងក្នុងទឹកល្បាយថ្នាំធ្វើឱ្យស ដែលបានរៀបចំរួចស្រេចឱ្យបាន៦០វិនាទី។**



**កុំលាងជម្រះក្នុងទឹកភ្លាមៗ បន្ទាប់ពីបានត្រាំពន្លិចក្នុងទឹកល្បាយថ្នាំធ្វើឱ្យស ដោយហេតុថាការនេះវាកាត់បន្ថយប្រសិទ្ធិភាពនៃទឹកថ្នាំធ្វើឱ្យស។**

លាងត្រដុសម្តងទៀតដូចបានណែនាំពេលណាចាកចេញពីទីចំការ។

ឱ្យបានដឹង។
ឱ្យបានសកម្ម។
ឱ្យមានការប្រុងប្រយ័ត្ន។



VICTORIA
State Government



សម្លៀកបំពាក់ និងមួក គឺជាវត្ថុចម្លងសត្វល្អិតចង្រៃ **phylloxera** ដែលមានហានិភ័យខ្ពស់ ដោយហេតុថាវត្ថុទាំងនេះអាចប៉ះពាល់ជាមួយដើមទំពាំងបាយជូរ ដូច្នេះសូមកាត់បន្ថយហានិភ័យឱ្យមានតិចបំផុត ដោយផ្តល់សម្លៀកបំពាក់ប្រើហើយបោះចោល ឬសម្លៀកបំពាក់ពិសេសដាក់លាក់នៅនឹងកន្លែងសម្រាប់អ្នកធ្វើការដើម្បីស្លៀកពាក់ កន្លែងណាដែលអាចធ្វើបាន។



ប្រសិនបើមិនប្រើប្រាស់សម្លៀកបំពាក់ប្រើហើយបោះចោលទេ ត្រូវមានការធានាថាអ្នកធ្វើការមានសម្លៀកបំពាក់ផ្លាស់ប្តូររវាងទីចំការ  ហើយសម្លៀកបំពាក់ដែលបានពាក់ក្នុងអំឡុងពេលធ្វើការ ត្រូវបោកគក់ក្នុងម៉ាស៊ីនបោកគក់មួយនៅកម្តៅ **50°C** ឬខ្ពស់ជាងនេះ ជាមួយនឹងសាប៊ូ មុនពេលប្រើប្រាស់ម្តងទៀត។ សម្លៀកបំពាក់ទាំងអស់ដែលបានប្រើប្រាស់ក្នុងចំការទំពាំងបាយជូរនៅ **PIZs** និង **PRZs** គួរតែបានដាក់ក្នុងថង់ប្លាស្ទិចបិទជិត សម្រាប់ការដឹកជញ្ជូន។ សម្លៀកបំពាក់ដែលមានផ្ទុកនូវសត្វល្អិតចង្រៃ មិនត្រូវដឹកបញ្ជូនទៅកាន់ទីចំការផ្សេងទៀត ហើយពាក់វិញឡើយ។



លាងសម្អាតឧបករណ៍ខ្នាតតូចប្រើប្រាស់នឹងដៃ ដូចជាឧបករណ៍សម្រាប់ចាប់រើស និងកាត់តម្រឹមមែកឈើតូចៗ នៅក្នុងទឹកថ្នាំធ្វើឱ្យស៥០ភាគរយ ទឹក៥០ភាគរយ ឱ្យបាន៦០វិនាទី។



ការអប់រំ និងបណ្តុះបណ្តាលបុគ្គលិក និងអ្នកម៉ៅការគឺមានសារៈសំខាន់ខ្លាំងណាស់។




រូវរៀបចំសន្លឹកព័ត៌មាន ហើយផលិតខ្សែវីឌីអូបណ្តុះបណ្តាលអំពីសត្វល្អិតចង្រៃ **phylloxera** ឱ្យមានរួចស្រេច។

© រដ្ឋវិចតូរីយ៉ា ក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច ការងារ ដឹកជញ្ជូន & ធនធាន

ខែវិច្ឆិកា ឆ្នាំ២០១៦

កិច្ចការនេះបានផ្តល់អាជ្ញាបណ្ណនៅក្រោមអាជ្ញាបណ្ណអូស្ត្រាលី Creative Commons Attribution 3.0។ លោកអ្នកអាចយកកិច្ចការនេះប្រើប្រាស់ឡើងវិញបានដោយសេរីនៅក្រោមអាជ្ញាបណ្ណនេះ ដោយមានលក្ខខណ្ឌថាលោកអ្នកត្រូវដាក់ការទទួលស្គាល់រដ្ឋវិចតូរីយ៉ាថាជាអ្នកនិពន្ធ។ អាជ្ញាបណ្ណនេះមិនអនុវត្តចំពោះរូបថត រូបភាពណាមួយ ឬឃីហោ រួមទាំងស្លាកសញ្ញារដ្ឋវិចតូរីយ៉ា រូបសញ្ញារដ្ឋាភិបាលវិចតូរីយ៉ា និងរូបសញ្ញាក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច ការងារ  ការដឹកជញ្ជូន & ធនធាន។ ដើម្បីពិនិត្យមើលច្បាប់ចម្លងនៃអាជ្ញាបណ្ណនេះ សូមបើកចូលវិបសាយ  http://creativecommons.org/licenses/by/3.0/au/deed.en

## ការទទួលបាន

ប្រសិនបើលោកអ្នកចង់ទទួលបានការបោះពុម្ពផ្សាយនេះ ក្នុងទ្រង់ទ្រាយផ្សេងទៀត សូមទូរស័ព្ទមជ្ឈមណ្ឌលសេវាអតិថិជន DEDJTR លេខ 136 186, អ៊ីម៉េល plant.standards@ecodev.vic.gov.au ឬតាមរយៈសេវាបញ្ជូនបន្តជាតិ លេខ 133 677 www.relayservice.com.au។ ឯកសារនេះគឺអាចរកបាននៅលើអ៊ីនធើណិត នៅត្រង់ www.agriculture.vic.gov.au/phylloxera

## ការមិនទទួលខុសត្រូវ

**ការបោះពុម្ពផ្សាយនេះអាចជាជំនួយដល់លោកអ្នក ក៏ប៉ុន្តែរដ្ឋវិចតូរីយ៉ា និងបុគ្គលិករបស់ខ្លួនមិនធានាថាការបោះពុម្ពផ្សាយនេះវាគ្មានកំហុសក្នុងប្រភេទណាមួយ ឬជាការសមស្របទាំងស្រុងនោះឡើយ សម្រាប់គោលបំណងជាក់លាក់របស់លោកអ្នក ហេតុដូច្នេះហើយមិនទទួលខុសត្រូវចំពោះការទាមទារទទួលខុសត្រូវទាំងអស់ សម្រាប់កំហុសណាមួយ ការខាតបង់ ឬផលវិបាកផ្សេងទៀតដែលអាចកើតឡើង ពីការពឹងផ្អែករបស់លោកអ្នកលើព័ត៌មានណាមួយនៅក្នុងការបោះពុម្ពផ្សាយនេះ។**

VICTORIA
State
Government

www.agriculture.vic.gov.au/phylloxera